**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិបណ្តុះបណ្តាល
National Training Board (NTB)

# កំណត់ហេតុប្រជុំ
# របស់
# គណៈកម្មាធិការជាតិបណ្តុះបណ្តាលលើកទី ៦

ឆ្នាំពីរពាន់ដប់ ខែធ្នូ ថ្ងៃទីម្ភៃប្រាំពីរ វេលាម៉ោងដប់ប្រាំមួយនាទីរសៀល នៅសាលប្រជុំ A នៃទីស្តីការគណៈរដ្ឋមន្ត្រីបានបើកអង្គប្រជុំគណៈកម្មាធិការជាតិបណ្តុះបណ្តាល (NTB) លើកទី៦ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តមបណ្ឌិតសភាចារ្យ សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងជាប្រធានគណៈកម្មាធិការជាតិបណ្តុះបណ្តាល ដែលមានសមាសភាពចូលរួម និងរបៀបវារៈនៃអង្គប្រជុំជូនភ្ជាប់មកជាមួយ ។

របៀបវារៈទី១

ជាកិច្ចចាប់ផ្តើម **ឯកឧត្តមប្រធានអង្គប្រជុំ** បានថ្លែងអំណរគុណដល់ឯកឧត្តម លោកជំទាវ លោក លោកស្រី ជំនាញការជាតិ និងអន្តរជាតិ ដែលមានវត្តមាននៅក្នុងអង្គប្រជុំនេះ និងបានលើកឡើងនូវបទបញ្ជា បីចំណុចរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ក្នុងវេទិកាភាពរដ្ឋាភិបាល-ផ្នែកឯកជនលើកទី១៥ ដែលបានប្រព្រឹត្តិទៅនៅថ្ងៃទី២៧ ខែមេសា ឆ្នាំ២០១០កន្លងមក តម្រូវឲ្យគណៈកម្មាធិការជាតិបណ្តុះបណ្តាលរៀបចំនូវសេចក្តីព្រាងរបាយការណ៍ដើម្បីឆ្លើយតបទៅនឹងបទបញ្ជាទាំងបីចំណុចរបស់ប្រមុខរាជរដ្ឋាភិបាលគឺ៖

- ទី១. វាយតម្លៃស្ថានភាពការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ និងលើកទិសដៅកែលម្អគុណភាពដើម្បីឆ្លើយតបតាមតម្រូវការទីផ្សារការងារ
- ទី២. រៀបចំសារាចរណែនាំស្តីពីការលើកកម្ពស់គុណភាព និងប្រសិទ្ធភាពនៃការងារអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ
- ទី៣. រៀបចំលើកគម្រោងផែនការបណ្តុះបណ្តាលកម្មករ កម្មការនីក្រោមគម្រោង **មូលនិធិពិសេសរបស់សម្តេចតេជោនាយករដ្ឋមន្ត្រី** នៅរាជធានីភ្នំពេញ ខេត្តព្រះសីហនុ ខេត្តសៀមរាប និងខេត្តមួយចំនួនទៀតដែលមានតំបន់សេដ្ឋកិច្ចពិសេស។

ឆ្លៀតក្នុងឱកាសនេះដែរ **ឯកឧត្តមប្រធានអង្គប្រជុំ** ក៏បានបញ្ជាក់ថា គម្រោង **មូលនិធិពិសេសរបស់សម្តេចតេជោនាយករដ្ឋមន្ត្រី** ត្រូវបានបញ្ចប់ដោយទទួលបានជោគជ័យ។ នៅក្នុងវេទិកានោះតំណាងឯកជន និងមជ្ឈដ្ឋានដែលពាក់ព័ន្ធផ្ទាល់បានសំណូមពរទៅ **សម្តេចតេជោ** ឲ្យមានមូលនិធិពិសេសនេះបន្តទៀតដល់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដើម្បីមានលទ្ធភាពធ្វើការបណ្តុះបណ្តាលជួយដល់កម្មករ កម្មការនី និងយុវជន យុវនារីដែលបាត់បង់ និងគ្មានការងារធ្វើ ។

ជាកិច្ចបន្ត **ឯកឧត្តមប្រធានអង្គប្រជុំ** បានមានប្រសាសន៍ថា បច្ចុប្បន្នសង្គម-សេដ្ឋកិច្ចមានការរីកវឌ្ឍន៍ឈានឡើង ដូច្នេះយើងក៏ត្រូវធ្វើឲ្យប្រព័ន្ធអប់រំរបស់យើងឈានឡើងផងដែរ។ ចំណុចនេះបានចោទជាបញ្ហាថ្មីដែលយើងបានលើកឡើងទៅក្នុងកម្មវិធីគោលនយោបាយដើម្បីធ្វើការដោះស្រាយ។ គេបានធ្វើការវាយតម្លៃរួចហើយទៅលើកម្មវិធី **អប់រំសម្រាប់ទាំងអស់គ្នា** ឃើញថា ជាង ៩០% ដែលជាកុមារា កុមារី របស់យើងបានទៅសាលារៀនចាប់ពី មត្តេយ្យរហូតដល់បញ្ចប់មធ្យមសិក្សាទុតិយភូមិ។ យោងតាមស្ថិតិច្បាស់លាស់ក្នុងឆ្នាំ២០១០ ចំនួនសិស្សដែលបានប្រឡងមធ្យមសិក្សាទុតិយភូមិមានចំនួនជាង ១០ម៉ឺននាក់ ក្នុងនោះមានចំនួនជាង ៨ម៉ឺននាក់ ប្រហែលជាង ៨០% បានប្រឡងជាប់ជាស្ថាពរ។ សិស្សដែលបានប្រឡងជាប់មួយចំនួនបានទទួលអាហារូបករណ៍ មួយចំនួនទៀតបានចូល

រៀននៅតាមសាកលវិទ្យាល័យឯកជននានា និងមួយចំនួនទៀតប្រហែលទៅធ្វើស្រែចំការវិញ និងប្រកបមុខរបរកសិកម្ម។ យើងត្រូវគិតគូរកេការងារឲ្យពួកគាត់ធ្វើ ចំពោះសិស្សដែលបានបញ្ចប់នៅសាកលវិទ្យាល័យ និងសិស្សចេញពីវិទ្យាល័យ ឬរៀនត្រឹមថ្នាក់ទី៩ ពីព្រោះបើយើងមិនរកការងារឲ្យពួកគាត់ធ្វើទេ វាជាបញ្ហាដ៏ធំមួយសម្រាប់រាជរដ្ឋាភិបាល។ ដូចនេះការងាររបស់គណៈកម្មាធិការជាតិបណ្តុះបណ្តាល ត្រូវរៀបចំផ្តល់វគ្គបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ដើម្បីឲ្យយុវជន យុវនារី ទាំងអស់នោះក្លាយទៅជាធនធានមនុស្សច្រើនប្រភេទ និងច្រើនកម្រិត ដែលទីផ្សារការងារ និងរដ្ឋបាលសាធារណៈត្រូវការ។ អ្វីដែលយើងតែងតែលើកឡើងថា ការផលិតធនធានមនុស្សត្រូវឆ្លើយតបទៅនឹងសេចក្តីត្រូវការ(Supply and Demand គឺឲ្យវាស្របគ្នា)។ ដើម្បីឲ្យឆ្លើយតបបញ្ហាខាងលើគណៈកម្មាធិការជាតិបណ្តុះបណ្តាលបានបង្កើត និងដំណើរការរួចហើយនូវទីភ្នាក់ងារជាតិមុខរបរ និងការងារ(NEA) ដែលអង្គភាពនេះមានការងារចំបងគឺ រកការងារឲ្យអ្នកដែលស្វែងរកការងារធ្វើ។

បន្ទាប់មកទៀត **ឯកឧត្តមប្រធានអង្គប្រជុំ** ក៏បានស្នើសុំឲ្យឯកឧត្តម លោកជំទាវ លោក លោកស្រី ជំនាញការជាតិ និងអន្តរជាតិ ចូលរួមបញ្ចេញនូវមតិយោបល់ និងអនុម័តនូវសេចក្តីព្រាងរបាយការណ៍របស់គណៈកម្មាធិការជាតិបណ្តុះបណ្តាល ដើម្បីឲ្យឆ្លើយតបទៅនឹងបទបញ្ជា ប៊ីចំណុចរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ប្រមុខរាជរដ្ឋាភិបាលកម្ពុជា។

របៀបវារៈទី២

**ឯកឧត្តមប្រធានអង្គប្រជុំ** ក៏បានអនុញ្ញាតឲ្យឯកឧត្តម **ឡៅ ហ៊ីម** អគ្គនាយកអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ និងជានាយកប្រតិបត្តិនៃគណៈកម្មាធិការជាតិបណ្តុះបណ្តាល ធ្វើការរាយការណ៍សង្ខេបជូនអង្គប្រជុំអំពីរបាយការណ៍បញ្ចប់គម្រោងនៃការបណ្តុះបណ្តាលជំនាញតាមលិខិតបញ្ជាក់ឆ្នាំ២០០៦-២០១០ (ESDP II) បន្ទាប់មកឯកឧត្តម **ឡៅ ហ៊ីម** បានធ្វើបទបង្ហាញលើចំណុចសំខាន់ៗមួយចំនួនដូចតទៅៈ

គម្រោងកម្មវិធីអភិវឌ្ឍន៍វិស័យអប់រំទី២ បានចាប់ផ្តើមអនុវត្តនៅខែសីហា ឆ្នាំ២០០៥ និងបានបញ្ចប់នៅខែមិថុនា ឆ្នាំ២០១០ គម្រោងនេះមានថវិកាសរុបចំនួន ៣៣.៦លានដុល្លាអាមេរិក ដែលមានអ្នកអនុវត្តគម្រោងពីរគឺក្រសួងអប់រំ យុវជន និងកីឡា និងក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។ សម្រាប់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈបានទទួលថវិកាសរុបមានចំនួន ៥,២លានដុល្លាអាមេរិក ក្នុងការអនុវត្តន៍គម្រោង។ គម្រោងនេះធ្វើការបណ្តុះបណ្តាលជំនាញតាមលិខិតបញ្ជាក់សាកល្បងលើ ៧ខេត្ត នៅក្នុង ២១០ឃុំដែលក្រីក្រជាងគេ ហើយថវិកាក្នុងឃុំនីមួយៗមានចំនួន ៩.០០០ដុល្លា/ឆ្នាំ ក្នុងរយៈពេលបីឆ្នាំ។ ការបណ្តុះបណ្តាលនេះមានលក្ខណៈ ៣ប្រភេទគឺតាមសហគមន៍ តាមសហគ្រាស និងតាមមជ្ឈមណ្ឌល។ គម្រោងបានកំណត់ចំនួនសិក្ខាកាមជាក្រុមគោលដៅសម្រាប់ការបណ្តុះបណ្តាលមានចំនួនសរុប ១២០.០០០នាក់ ជាក់ស្តែងលទ្ធផលនៃការបណ្តុះបណ្តាលសិក្ខាកាមមានចំនួនរហូតដល់ ១៦១.៣៨៩នាក់ លើសផែនការមានចំនួន ៣៤,៤៩ភាគរយ (គិតដល់ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១០ សម្រេចបាន ១៣៤.៤៩ភាគរយ ក្នុងនេះមានស្ត្រី ៥៨,០៧ភាគរយ)។ មូលហេតុដែលលើសនេះដោយសារការបណ្តុះបណ្តាលនៅក្នុង ១វគ្គមាន ៣០នាក់ ប៉ុន្តែសហគមន៍មានតម្រូវការច្រើន ហើយពួកគាត់បានស្នើសុំចូលរៀនបន្ថែម មានន័យថា ១វគ្គ មានសិក្ខាកាមគឺ ៣៥ ឬ ៣៧នាក់ សរុបជារួមឃើញថាចំនួនសិក្ខាកាមកើនឡើង ប៉ុន្តែទឹកប្រាក់សម្រាប់ការបណ្តុះបណ្តាលនៅដដែល។ អត្រាសិស្សដែលមានការងារធ្វើបន្ទាប់ពីបណ្តុះបណ្តាលចប់បាន ៣ខែ នៅសហគមន៍មាន ៦៥ភាគរយ តាមមជ្ឈមណ្ឌលមាន ៦២ភាគរយ និងតាមសហគ្រាសមាន ៧២ភាគរយ។ ហើយប្រាក់ចំណូលជាមធ្យមមុនការបណ្តុះបណ្តាលចំនួន ៩៥.៨៥០រៀល($២៤,៧០)ក្នុងមួយខែ បន្ទាប់ពីបណ្តុះបណ្តាលចប់បាន ៣ខែ គិតជាមធ្យមប្រាក់ចំណូលចំនួន ១៥១.១៩២រៀល($៣៧,៨០)ក្នុងមួយខែ និងបណ្តុះបណ្តាលចប់បាន ៦ខែ ប្រាក់ចំណូលកើនឡើងបាន ៤៩ដុល្លាអាមេរិក ឬប្រមាណ ៩៨ភាគរយ លើប្រាក់ចំណូលជាមូលដ្ឋាន។ ដោយសារកម្មវិធីអភិវឌ្ឍន៍វិស័យអប់រំទី២ ទទួលបានជោគជ័យខ្ពស់ទាំង ៧ខេត្ត ADBនឹងពង្រីកការបណ្តុះបណ្តាល

តាមលិខិតបញ្ជាក់ទូទាំង ២៤រាជធានី-ខេត្ត តាមរយៈការផ្តល់គម្រោងថ្មីគឺ គម្រោងពង្រឹងវិស័យអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ(STVET)។

របៀបវារៈទី៣

**ឯកឧត្តមប្រធានអង្គប្រជុំ** ក៏បានអនុញ្ញាតឲ្យឯកឧត្តម **ឡៅ ហ៊ីម** អគ្គនាយកអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ និងជានាយកប្រតិបត្តិនៃគណៈកម្មាធិការជាតិបណ្តុះបណ្តាល ធ្វើការរាយការណ៍សង្ខេបជូនអង្គប្រជុំអំពីរបាយការណ៍ពីគម្រោងពង្រឹងវិស័យអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ និងស្នើសុំការអនុម័តគម្រោងតាមឃុំ និងថវិកាសម្រាប់បណ្តុះបណ្តាលជំនាញតាមលិខិតបញ្ជាក់ឆ្នាំ២០១១ ជំហានទី១ ៧ខេត្តមុនគឺ ខេត្តបាត់ដំបង ខេត្តកំពង់ឆ្នាំង ខេត្តស្វាយរៀង ខេត្តកំពត ខេត្តសៀមរាប ខេត្តស្ទឹងត្រែង និងខេត្តតាកែវ របស់គម្រោង STVET ហើយឯកឧត្តម **ឡៅ ហ៊ីម** បានធ្វើបទបង្ហាញលើចំណុចសំខាន់ៗមួយចំនួនដូចតទៅ៖

គម្រោងពង្រឹងវិស័យអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ បានចាប់ផ្តើមអនុវត្តនៅខែកុម្ភៈ ឆ្នាំ២០១០ នឹងត្រូវបញ្ចប់នៅខែកក្កដា ឆ្នាំ២០១៥ គម្រោងនេះមានថវិកាសរុបចំនួន ២៧,៥២លានដុល្លាអាមេរិក ក្នុងនោះថវិកាជំនួយឥតសំណងពីធនាគារអភិវឌ្ឍន៍អាស៊ី(ADB)ចំនួន ២៤,៥០លានដុល្លាអាមេរិក និងថវិកាបដិភាគពីរាជរដ្ឋាភិបាលចំនួន ៣,០២លានដុល្លាអាមេរិក។ គម្រោងនេះបានគាំទ្រដល់យុទ្ធសាស្ត្ររបស់រដ្ឋាភិបាលក្នុងការកាត់បន្ថយភាពក្រីក្រ និងសម្រេចនូវការអភិវឌ្ឍន៍ជំនាញដែលជាតម្រូវការទីផ្សារការងារទាំងនៅក្នុង និងក្រៅប្រព័ន្ធសេដ្ឋកិច្ច ដែលមានបីផ្នែកគឺ យន្តសាស្ត្រ សំណង់ ពាណិជ្ជសាស្ត្រ និងបច្ចេកវិទ្យាទំនាក់ទំនង(ICT)។ គម្រោងនេះមាន បីសមាសភាគ ទី១៖ លើកកម្ពស់គុណភាព និងទទួលបានការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈក្នុងប្រព័ន្ធ (កម្មវិធីដែលទាក់ទងច្រើនទៅនឹងឧស្សាហកម្ម) ទី២៖ ពង្រីក និងធ្វើឲ្យប្រសើរឡើងនូវគុណភាពអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈក្រៅប្រព័ន្ធ និងទី៣៖ ពង្រឹងសមត្ថភាពគ្រឹះស្ថានក្នុងការគ្រប់គ្រង និងរៀបចំផែនការ TVET។ គម្រោងតម្រូវឲ្យធ្វើការបណ្តុះបណ្តាលជំនាញតាមលិខិតបញ្ជាក់នៅក្នុងឆ្នាំ២០១១ ជំហានទី១ ដែលយើងបានចាប់ផ្តើម ៧ខេត្តមុនគឺ ខេត្តបាត់ដំបង ខេត្តកំពង់ឆ្នាំង ខេត្តកំពត ខេត្តសៀមរាប ខេត្តស្ទឹងត្រែង ខេត្តស្វាយរៀង និងខេត្តតាកែវ ក្នុងនោះមាន ២០៩ឃុំ ក្នុងចំណោម ៥៥ស្រុក ហើយថវិកាក្នុងឃុំនីមួយៗមានចំនួន ៥.៧៨៦ដុល្លា/ឆ្នាំ មានរយៈពេលបណ្តុះបណ្តាលចំនួន ពីរឆ្នាំ។ បន្ទាប់មក ឯកឧត្តម បានស្នើសុំការអនុម័តយល់ព្រមពី NTB លើថវិកាសម្រាប់ធ្វើការបណ្តុះបណ្តាលជំនាញតាមលិខិតបញ្ជាក់ឆ្នាំ២០១១ ជំហានទី១ ដែលមានចំនួនសរុប ១.២០៩.២៧៤ដុល្លាអាមេរិក។

របៀបវារៈទី៤

**ឯកឧត្តមប្រធានអង្គប្រជុំ** ក៏បានអនុញ្ញាតឲ្យឯកឧត្តម **ឡៅ ហ៊ីម** អគ្គនាយកអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ និងជានាយកប្រតិបត្តិនៃគណៈកម្មាធិការជាតិបណ្តុះបណ្តាល ធ្វើការរាយការណ៍សង្ខេបជូនអង្គប្រជុំអំពីគម្រោងសាកល្បងលើបច្ចេកទេសក្រោយប្រមូលផល និងកម្មវិធីស្ពានចម្លងបន្តជំនាញ (PHT-SBP) ហើយក្នុងនោះឯកឧត្តម **ឡៅ ហ៊ីម** បានធ្វើបទបង្ហាញលើចំណុចសំខាន់ៗមួយចំនួនដូចតទៅ៖

គម្រោងសាកល្បងលើបច្ចេកទេសក្រោយប្រមូលផល និងកម្មវិធីស្ពានចម្លងបន្តជំនាញសម្រាប់ជនបទក្រីក្របានចាប់ផ្តើមអនុវត្តពីខែកក្កដា ឆ្នាំ២០០៩ ដល់ថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០១២ ប្រើប្រាស់ថវិកាចំនួន ២.៣២០.០០០ដុល្លាអាមេរិក។ ថវិកាចំនួន ១.១៥៥.០០០ដុល្លាអាមេរិក សម្រាប់គម្រោងសាកល្បងលើបច្ចេកទេសក្រោយប្រមូលផល ដោយបានធ្វើការសាកល្បងលើគ្រឹះស្ថានសិក្សា បួន ក្នុងនោះមាន វិទ្យាស្ថានពហុបច្ចេកទេសខេត្តបាត់ដំបងចំនួន ១២ឃុំ វិទ្យាស្ថានពហុបច្ចេកទេសខេត្តកំពតចំនួន ១៥ឃុំ មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តសៀមរាបចំនួន ១២ឃុំ និងវិទ្យាស្ថានជាតិពហុបច្ចេកទេសកម្ពុជាចំនួន ៥ឃុំ ដោយជ្រើសរើសអ្នកភូមិជាក្រុមគោលដៅចំនួន ៣.០០០នាក់ នៅក្នុង ៤៤ឃុំ។ ជាលទ្ធផលនៃការអនុវត្តន៍កន្លងមក ចំនួនសិស្សដែលបានបណ្តុះបណ្តាលលើជំនាញបច្ចេកទេសក្រោយប្រមូលផល និងការកែច្នៃចំណីអាហារគិតដល់ខែធ្នូ ឆ្នាំ២០១០ មានចំនួន ៣៧ឃុំ ក្នុងចំណោម ១៦ស្រុក លើ ៣៣

មុខបន្លែ ផ្លែឈើ និងការកែច្នៃចំណីអាហារ ៣៣ជំនាញ ដែលមានសិក្ខាកាមសរុបចំនួន ៩៣៩នាក់ ក្នុងនោះស្ត្រីមានចំនួន ៥១៥នាក់។ ថវិកាចំនួន ៣៦០.០០០ដុល្លាអាមេរិក សម្រាប់គម្រោងកម្មវិធីស្ពានចម្លងបន្តជំនាញ ដោយធ្វើការសាកល្បងលើគ្រឹះស្ថានសិក្សា បី ក្នុងនោះមាន វិទ្យាស្ថានពហុបច្ចេកទេសខេត្តកំពត វិទ្យាស្ថានពហុបច្ចេកទេសខេត្តបាត់ដំបង និងវិទ្យាស្ថានជាតិបណ្តុះបណ្តាលបច្ចេកទេស ដោយជ្រើសរើសសិស្សជាក្រុមគោលដៅចំនួន ៧០០នាក់ (ឆ្នាំ២០០៩-២០១២)។ ជាលទ្ធផលសិស្សដែលបានប្រឡងជាប់ជាស្ថាពរនៅក្នុងកម្មវិធីស្ពានចម្លងបន្តជំនាញមានចំនួនសរុប ២៦៧នាក់។ ថវិកាចំនួន ៤២១.០០០ដុល្លាអាមេរិក សម្រាប់គម្រោងបំប៉នសមត្ថភាពការគ្រប់គ្រង និងការត្រួតពិនិត្យ ជាលទ្ធផលយើងបានធ្វើ ទី១៖ សិក្ខាសាលាស្តីពីការពង្រឹងសមត្ថភាពដល់គ្រឹះស្ថានគោលដៅទាំង៤ និងមន្ត្រីអង្គភាពសម្របសម្រួលគម្រោង ដែលមានសិក្ខាកាមចូលរួមចំនួន ៣០នាក់ ទី២៖ បានរៀបចំវគ្គបណ្តុះបណ្តាលគ្រូបង្គោល(TOT) ដល់គ្រឹះស្ថានគោលដៅទាំង៤ និងមន្ត្រីអគ្គនាយកដ្ឋានដែលមានសិក្ខាកាមចូលរួមចំនួន ២០នាក់ និងទី៣៖ បានរៀបចំពិធីតាំងពិព័ណ៌ផលិតផលកែច្នៃចំណីអាហារ នៅមជ្ឈមណ្ឌលតាំងពិព័រណ៍កោះពេជ្រដែលមានរយៈពេល ៤ថ្ងៃ។

របៀបវារៈទី៥

**ឯកឧត្តមប្រធានអង្គប្រជុំ** ក៏បានអនុញ្ញាតឲ្យឯកឧត្តម **ហុង ជឿន** ប្រធានទីភ្នាក់ងារជាតិមុខរបរនិងការងារ (NEA) ធ្វើការរាយការណ៍សង្ខេបជូនអង្គប្រជុំអំពីលទ្ធផលការងាររបស់ទីភ្នាក់ងារជាតិមុខរបរ និងការងារ ហើយក្នុងនោះឯកឧត្តម **ហុង ជឿន** បានលើកឡើងនូវចំណុចសំខាន់ៗមួយចំនួនដូចខាងក្រោម ៖

ទីភ្នាក់ងារជាតិមុខរបរ និងការងារ បានបង្កើតដោយអនុក្រឹត្យលេខ ៦៧អនក្រ.បក ចុះថ្ងៃទី២៧ ខែមេសា ឆ្នាំ២០០៩ ជាទីភ្នាក់ងារប្រតិបត្តិការពិសេស(Special Operating Agency) ស្ថិតនៅក្រោមគណៈកម្មាធិការជាតិបណ្តុះបណ្តាល។ គោលបំណងក្នុងការបង្កើតឲ្យមានទីភ្នាក់ងារជាតិមុខរបរ និងការងារ គឺដើម្បីផ្តល់សេវាការងារ និងព័ត៌មានទីផ្សារការងារប្រកបដោយគុណភាព និងប្រសិទ្ធភាព ដល់អ្នកស្វែងរកការងារធ្វើ និយោជិត និយោជក អ្នកផ្តល់ការអប់រំបណ្តុះបណ្តាលជំនាញ អ្នករៀបចំគោលនយោបាយ និងផែនការ និងសាធារណៈជនទូទៅ។ ជាលទ្ធផលនៃការអនុវត្តន៍ការងារគិតចាប់ពីថ្ងៃទី០៥ ខែមីនា ដល់ថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០១០ ទីភ្នាក់ងារជាតិមុខរបរ និងការងារ សម្រេចបានការងារមួយចំនួនដូចខាងក្រោម៖

- បានរៀបចំហេដ្ឋារចនាសម្ព័ន្ធ និងបំពាក់សម្ភារៈសម្រាប់ចាប់ផ្តើមដំណើរការ NEA
- បានបង្កើតគេហទំព័រ និងទំព័រការងារដែលមានកម្មវិធីផ្ទួងដោយស្វ័យប្រវត្តិ
- រៀបចំទម្រង់ចុះឈ្មោះសម្រាប់អ្នកស្វែងរកការងារធ្វើ និយោជក និងអ្នកផ្តល់ការអប់រំបណ្តុះបណ្តាល
- រៀបចំចងក្រងឯកសារសម្រាប់ណែនាំអំពីការត្រៀមលក្ខណៈស្វែងរកការងារធ្វើ
- បានបង្កើតមជ្ឈមណ្ឌលការងារនៅរាជធានីភ្នំពេញ ខេត្តបាត់ដំបង ខេត្តសៀមរាប និងខេត្តកំពត
- បានបង្កើតបន្ទប់នៅក្នុងមជ្ឈមណ្ឌលការងារសម្រាប់និយោជកធ្វើការសម្ភាសន៍
- បង្កើតបណ្ណាល័យការងារដែលមានសៀវភៅចំនួន ១.១២០ក្បាល
- ធ្វើបច្ចុប្បន្នកម្ម និងបញ្ចូលព័ត៌មានពាក់ព័ន្ធនឹងទីផ្សារការងាររៀងរាល់ថ្ងៃលើគេហទំព័ររបស់ NEA
- ទទួលបានអ្នកមកមើលព័ត៌មានដែលផ្សព្វផ្សាយនៅលើក្តារប្រកាសចំនួន១២.៦៨០នាក់
- ទទួលបានអ្នកមើលគេហទំព័ររបស់ NEA ចំនួន ៣៣.២៦៨នាក់
- ចុះឈ្មោះអ្នកស្វែងរកការងារធ្វើសរុបបានចំនួន ២.២៩៧នាក់
- បើកវគ្គបណ្តុះបណ្តាលណែនាំអ្នកស្វែងរកការងារធ្វើមុនបញ្ជូនទៅឲ្យនិយោជកចំនួន ៦០៧នាក់
- បញ្ជូនអ្នកស្វែងរកការងារធ្វើទៅឲ្យនិយោជកបានចំនួន ១.៥៤៨នាក់
- រកការងារឲ្យអ្នកស្វែងរកការងារធ្វើបានចំនួន ១៣២នាក់

- បានធ្វើយុទ្ធនាការបង្កើនការយល់ដឹងជាសាធារណៈ និងការប្រើប្រាស់សេវាតាមរយៈការរៀបចំ និងបោះពុម្ពប័ណ្ណផ្សព្វផ្សាយ ធ្វើសិក្ខាសាលា និងចុះផ្សព្វផ្សាយដល់គ្រឹះស្ថានឧត្តមសិក្សា និងអប់រំបណ្ដុះបណ្ដាលបច្ចេកទេស និងវិជ្ជាជីវៈ ចូលរួមពិព័រណ៍ការងារ ចុះជួបនិយោជកផ្ទាល់ និងធ្វើការផ្សព្វផ្សាយពាណិជ្ជកម្មតាមទំព័រសារព័ត៌មាន
- បានរៀបចំអនុក្រឹត្យស្ដីពី ការប្រមូលចងក្រងព័ត៌មានទីផ្សារការងារ ដែលទទួលបានការអនុម័តពីរាជរដ្ឋាភិបាលនៅថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០១០
- បានរៀបចំកម្រងសំណួរស្ដីពីតម្រូវការធនធានមនុស្សរបស់ក្រសួង ស្ថាប័ន សម្រាប់ឆ្នាំ២០១១-២០១៥ ដែលក្រសួង ស្ថាប័ន ត្រូវបញ្ជូនត្រឡប់ឲ្យ NEA វិញនៅត្រឹមថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០១១
- បានបណ្ដុះបណ្ដាលអភិវឌ្ឍន៍សមត្ថភាពមន្ត្រីតាមរយៈការបញ្ជូនមន្ត្រីទៅចូលរួមវគ្គបណ្ដុះបណ្ដាល និងទស្សនកិច្ចសិក្សានៅក្នុង និងក្រៅប្រទេសដូចជាប្រទេសអ៊ីតាលី និងប្រទេសចិន

បន្ថែមលើនេះឯកឧត្ដម **ហុង ជឿន** បានលើកឡើងនូវទិសដៅអនុវត្តក្នុងឆ្នាំ២០១១ ដែលមានចំណុចសំខាន់ៗចំនួន៥ និងបានលើកឡើងនូវសំណូមពរដល់ NTB ធ្វើការកែសម្រួលអនុក្រឹត្យលេខ ៦៧ អនក្រ.បក ចុះថ្ងៃទី២៧ ខែមេសា ឆ្នាំ២០០៩ ស្ដីពីការបង្កើតទីភ្នាក់ងារជាតិមុខរបរ និងការងារ ដើម្បី៖

- អនុញ្ញាតឲ្យទីភ្នាក់ងារជាតិមុខរបរ និងការងារ មានត្រា និង Logo
- កំណត់ឋានៈប្រធានក្រុមការងារ និងប្រធានមជ្ឈមណ្ឌលការងារស្មើប្រធានការិយាល័យ
- ផ្ដល់ប្រាក់ឧបត្ថម្ភបន្ថែម និងការលើកទឹកចិត្តដល់មន្ត្រីឲ្យសមស្របតាមគោលការណ៍ SOA ។

របៀបវារៈទី៦

**ឯកឧត្ដមប្រធានអង្គប្រជុំ** ក៏បានអនុញ្ញាតឲ្យលោក **ឃិន ចន្ធា** ប្រធាននាយកដ្ឋានគ្រប់គ្រងកិច្ចការអប់រំបណ្ដុះបណ្ដាលបច្ចេកទេស និងវិជ្ជាជីវៈ ធ្វើការរាយការណ៍សង្ខេបជូនអង្គប្រជុំអំពីការវាយតម្លៃស្ថានភាពការអប់រំបណ្ដុះបណ្ដាលបច្ចេកទេស និងវិជ្ជាជីវៈ និងលើកទិសដៅកែលម្អគុណភាពដើម្បីឆ្លើយតបតាមតម្រូវការទីផ្សារការងារ ហើយក្នុងនោះលោក **ឃិន ចន្ធា** បានលើកឡើងនូវចំណុចសំខាន់ៗមួយចំនួនដូចខាងក្រោម៖

នៅក្នុងវេទិការាជរដ្ឋាភិបាល-ផ្នែកឯកជនលើកទី១៥ នាថ្ងៃទី២៧ ខែមេសា ឆ្នាំ២០១០ បានប្រគល់ភារកិច្ចជូនដល់គណៈកម្មាធិការជាតិបណ្ដុះបណ្ដាលបង្កើតក្រុមការងារមួយ សម្រាប់ធ្វើការវាយតម្លៃស្ថានភាពការអប់រំបណ្ដុះបណ្ដាលបច្ចេកទេស និងវិជ្ជាជីវៈ និងលើកទិសដៅកែលម្អគុណភាពដើម្បីឆ្លើយតបតាមតម្រូវការទីផ្សារការងារ ក្នុងគោលបំណងដើម្បីពិនិត្យមើលទិដ្ឋភាពរួមក្នុងពេលបច្ចុប្បន្នរបស់មជ្ឈមណ្ឌលបណ្ដុះបណ្ដាលវិជ្ជាជីវៈ ដោយសង្កត់ធ្ងន់លើភាពខ្លាំង ភាពខ្សោយ និងទស្សនៈវិស័យទៅអនាគត ដើម្បីលើកអនុសាសន៍ជូនរាជរដ្ឋាភិបាលចាត់វិធានការដោះស្រាយទាំងផ្នែកនយោបាយ និងផ្នែកគតិយុត្តិសំដៅលើកកម្ពស់ការអប់រំបណ្ដុះបណ្ដាលបច្ចេកទេស និងវិជ្ជាជីវៈនៅកម្ពុជាឲ្យសមស្របតាមតម្រូវការទីផ្សារការងារ។ ដើម្បីសម្រេចបាននូវគោលបំណងនៃការសិក្សានេះ ក្រុមការងារវាយតម្លៃរបស់គណៈកម្មាធិការជាតិបណ្ដុះបណ្ដាលបានប្រើប្រាស់វិធីសាស្ត្រ ពីរយ៉ាងគឺ ការសិក្សាពិនិត្យលើឯកសារដែលមានស្រាប់ និងការចុះទៅសិក្សាពិនិត្យវាយតម្លៃដល់ទីកន្លែង។ តាមរយៈការសិក្សាវាយតម្លៃរបស់ក្រុមការងារបានបង្ហាញឲ្យឃើញចំណុចមួយចំនួនសម្រាប់ធ្វើការវាយតម្លៃដូចខាងក្រោម៖

១. ការអប់រំបណ្ដុះបណ្ដាលបច្ចេកទេស និងវិជ្ជាជីវៈត្រូវឆ្លើយតបទៅនឹងតម្រូវការទីផ្សារការងារ
២. ការធានាគុណភាពបណ្ដុះបណ្ដាលសំដៅបង្កើនផលិតភាព
៣. ការពង្រឹងភាពដៃគូរវាងរដ្ឋ និងឯកជនក្នុងវិស័យអប់រំបណ្ដុះបណ្ដាលបច្ចេកទេស និងវិជ្ជាជីវៈ
៤. សមធម៌ក្នុងការបណ្ដុះបណ្ដាល
៥. ការលើកកម្ពស់ប្រព័ន្ធអប់រំបណ្ដុះបណ្ដាលបច្ចេកទេស និងវិជ្ជាជីវៈដើម្បីអភិវឌ្ឍសង្គម-សេដ្ឋកិច្ច